# ១. ឈ្វេងយល់ពីប្រព័ន្ធអេកូស៊ីស្ដឹមសង្គមស៊ីវិលនៅក្នុងខេត្តចំនួន ៤

From
the People of Japan

UNDP

ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស I ១២ I ២០២១

## គម្រោង
## ការកសាងសមត្ថភាពសម្រាប់ការចូលរួមរបស់ពលរដ្ឋ ការកសាងសន្តិភាព និងកិច្ចសន្ទនាប្រកបដោយបរិយាបន្ន៖ ឆ្ពោះទៅរកអភិបាលកិច្ចប្រកបដោយបរិយាបន្ន និងការចូលរួម អនុវត្តដោយ UNDP

សង្គមស៊ីវិល គឺជាវិស័យដ៏សំខាន់ដែលមានតួអង្គចម្រុះជាច្រើន។ តួអង្គទាំងនេះមានមុខងារផ្សេងៗគ្នា និងមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក។ ដូច្នេះ តាមរយៈគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព UNDP មានបំណងឈ្វេងយល់ពីប្រព័ន្ធអេកូស៊ីស្ដឹមសង្គមស៊ីវិល ក្នុងខេត្តកំពង់ចាម កំពត រតនគិរី និងសៀមរាប (សូមមើលរូបភាពអំពីកម្រិតទាំង ៤ នៃការអភិវឌ្ឍសមត្ថភាព)។

ក្នុងខេត្តទាំង ៤ នេះ បញ្ហាប្រឈមសំខាន់ជាងគេនៃប្រព័ន្ធអេកូស៊ីស្ដឹមរបស់សង្គមស៊ីវិល គឺលទ្ធភាពហិរញ្ញវត្ថុ (៥១% នៃអ្នកតបសម្ភាសដាក់ពិន្ទុចន្លោះពី ១ ទៅ ២)។ បន្ទាប់មក គឺការស្វែងរកមតិគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធតាមវិស័យរបស់សង្គមស៊ីវិល។ ជាជំហានបន្ទាប់ UNDP នឹងគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពនៅកម្រិតប្រព័ន្ធអេកូស៊ីស្ដឹម ផ្ដោតលើបញ្ហាប្រឈម ដែលត្រូវបានកំណត់។




កម្រិតទាំង ៤ នៃការកសាងសមត្ថភាព (ប្រភព Nesta ការរៀនសូត្រអំពីនវានុវត្តន៍)




ប្រភព៖ ការអង្កេតរៀបចំផែនទីបង្ហាញពីប្រព័ន្ធអេកូស៊ីស្ដឹម ខែសីហា ឆ្នាំ ២០២១

ពិន្ទុ ១-៥៖ សំណួរនៃការអង្កេតភាគច្រើន អំពីសមាសភាគនីមួយៗ ត្រូវបានឆ្លើយជាមួយនឹងការដាក់ពិន្ទុចន្លោះពី ១ ទៅ ៥ ដើម្បីបង្ហាញពីការយល់ស្របតាមសំណួរ (១ = មិនទាល់តែសោះ, ២ = តិចតួច, ៣ = ខ្លះ, ៤ = ច្រើន, ៥ = ទាំងស្រុង)។ ហើយពិន្ទុ ១-៥ នេះមានន័យថា ១ (បញ្ហាប្រឈមជាងគេ ចំពោះនិរន្តរភាពនៃអង្គការសង្គមស៊ីវិល) រហូតដល់ ៥ (ស្ថានភាពវិជ្ជមានជាងគេ ចំពោះនិរន្តរភាពនៃអង្គការសង្គមស៊ីវិល)




## ២. ការណែនាំអំពីភាពជាសហគ្រិន

អ្វីទៅដែលហៅថា ភាពជាសហគ្រិន? តើវាជួយអង្គការសង្គមស៊ីវិលនៅកម្ពុជាយ៉ាងដូចម្ដេចខ្លះ? នេះគឺជាប្រធានបទនៅក្នុងកម្មវិធីវេប៊ីណាជាស៊េរីស្ដីពី កត្តាជំរុញឱ្យមាននវានុវត្តន៍សង្គម រៀបចំដោយ UNDP សម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងខេត្តកំពង់ចាម កំពត រតនគិរី និងសៀមរាប។ ភាពជាសហគ្រិន សំដៅលើការធ្វើសកម្មភាពក្នុងស្មារតីសហគ្រិនភាពនៅក្នុងអង្គការមួយដែលត្រូវបង្កើតរួចហើយ។ ឧទាហរណ៍ ការកសាងធុរកិច្ចថ្មីនៅក្នុងអង្គការដោយប្រើប្រាស់ធនធានដែលមានស្រាប់ ដើម្បីបង្កើតសេវា និងផលិតផលថ្មីៗ ដែលមិនធ្លាប់ធ្វើឡើងកន្លងមក ឬតាមរយៈការប្រើប្រាស់អភិក្រមការងារផ្សេងខុសពីមុន។[១]

លោកស្រី នឿ សុវត្ថា នាយកអង្គការ CARE ប្រចាំប្រទេសកម្ពុជា មានប្រសាសន៍ថា «អង្គការសង្គមស៊ីវិលចាំបាច់ត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់ពលរដ្ឋ និងបន្តអភិវឌ្ឍខ្លួន។ ហើយភាព ជាសហគ្រិននឹងជួយឱ្យអង្គការសង្គមស៊ីវិលបន្តសម្រេចបានការរីកចម្រើននៅក្នុងអង្គការរបស់ខ្លួន និងធានាថាអង្គការទាំងនេះនៅតែមានភាពពាក់ព័ន្ធ និងមានភាពធន់។»

ដំបូន្មានសម្រាប់លើកកម្ពស់ភាពជាសហគ្រិន

- ស្វែងរកអ្វីដែលអ្នកធ្វើបានល្អបំផុតជាងគេ៖ តើអ្វីទៅដែលអង្គការមិនមែនរដ្ឋាភិបាលរបស់អ្នកធ្វើបានល្អបំផុតជាងគេនៅក្នុងទីផ្សារ និងតើអាចបំប្លែងអ្វីដែលអ្នកធ្វើល្អបំផុតនេះ ទៅជាសេវាដែលមានលក្ខណៈពាណិជ្ជកម្មដែរឬទេ?
- បែងចែករចនាសម្ព័ន្ធរវាងអង្គការមិនមែនរដ្ឋាភិបាល និងសហគ្រាសសង្គមរបស់អ្នក៖ ស្ថាប័នទាំងពីរនេះចាំបាច់ត្រូវតែមានផ្នត់គំនិតពីរផ្សេងពីគ្នា និងរបៀបធ្វើការងារផ្សេងគ្នាដែរ។
- បង្កភាពងាយស្រួលសម្រាប់ភាពជោគជ័យ៖ ផែនទីបង្ហាញផ្លូវរបស់អ្នក ដើម្បីសម្រេចជោគជ័យ គួរជាអ្វីដែលគេងាយស្រួលយល់។ សំខាន់ណាស់ដែលត្រូវអបអរសាទររាល់សមិទ្ធផលគ្រប់បែបយ៉ាង ដែលអ្នកសម្រេចបាន នេះគឺសម្រាប់ការកសាងក្រុមផង និងយុទ្ធសាស្ត្រសម្រាប់ផ្ដល់ការលើកទឹកចិត្តផង។
- វិនិយោគលើការងារផ្សព្វផ្សាយ និងទំនាក់ទំនង៖ ធ្វើឱ្យសហគ្រាសរបស់អ្នកមានឈ្មោះល្បី។
- ធ្វើប្រព្រឹត្តិកម្មយុទ្ធសាស្ត្រគៀគរមូលនិធិសម្រាប់សហគ្រាសរបស់អ្នក និងអង្គការមិនមែនរដ្ឋាភិបាល។

## ៣. ទុកការសន្និម៉ត់មួយឡែកសិន ដើម្បីស្ដាប់

ការរចនាការស្ដាប់ ដែលមានការសម្របសម្រួល (ហៅកាត់ថា FLD) គឺជាអភិក្រមដែលត្រូវបានបង្កើតឡើងនៅកម្ពុជា ក្រោមការផ្ដួចផ្ដើមគំនិតរបស់អង្គការស្ត្រីអ្នកកសាងសន្តិភាព (WPM)។ FLD បញ្ចូលការស្រាវជ្រាវ ដែលមានការចូលរួមទៅក្នុងក្របខណ្ឌស្ដីពីការស្ដាប់ ដើម្បីជំរុញការចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ឱ្យកាន់តែស៊ីជម្រៅ តាមរយៈការសន្ទនាជាមួយ អ្នកដែលរងផលប៉ះពាល់ដោយសារបញ្ហាជាក់លាក់។ FLD គឺជាអភិក្រមបង្កើតឡើងដោយអ្នកចូលរួមពាក់ព័ន្ធ និងកំណត់គោលដៅដែលគេអាចកែសម្រួលទៅតាមការចាំបាច់។ អភិក្រមនេះមានគោលបំណង ឈ្វេងយល់ឱ្យកាន់តែប្រសើរ ពីការយល់ឃើញផ្សេងៗគ្នារបស់អ្នកពាក់ព័ន្ធតាមរយៈការស្ដាប់បែបសកម្ម និងឈ្វេងយល់ពីអ្វីដែលមនុស្សកំពុងគិត និងរបៀបគិតរបស់ពួកគេ។ ម្យ៉ាងទៀត មានការខិតខំប្រឹងប្រែងយ៉ាងច្រើន ដើម្បីប្រើប្រាស់ការសន្ទនាសំដៅធ្វើឱ្យទំនាក់ទំនងកាន់តែមានភាពល្អប្រសើរ តាមរយៈការយល់ពីស្ថានភាពគ្នាទៅវិញទៅមក បើទោះជាវាមិនមែនមានន័យថា ជាការឯកភាពគ្នាក៏ដោយ។ ភាពចម្រុះនៃការយល់ឃើញ គឺជាគុណតម្លៃដ៏សំខាន់ក្នុងអភិក្រម FLD ហើយការមិនឯកភាពគ្នាដែលល្អ ត្រូវបានចាត់ទុកថាជាអ្វីដែលមានអត្ថន័យ និងរួមចំណែកនាំមកនូវផលិតភាព និងការសំឡឹងទៅអនាគត។

អង្គការ WPM កំពុងសម្របសម្រួលដំណើរការ FLD ជាមួយនឹងអ្នកចូលរួមមកពីអង្គការសង្គមស៊ីវិល រាជរដ្ឋាភិបាល និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីស្ដាប់ និងយល់ឱ្យកាន់តែប្រសើរពីការយល់ឃើញផ្សេងៗគ្នា អំពីការចូលរួមរបស់អង្គមស៊ីវិល និងរាជរដ្ឋាភិបាល។

សូមស្វែងរកព័ត៌មានបន្ថែមទៀតតាមរយៈគេហទំព័រ

@ - https://bit.ly/3rqRSgs




១. MIT Management Sloan School, https://mitsloan.mit.edu/ideas-made-to-matter/intrapreneurship-explained